# របាយការណ៍ស្តីពី
# ប្រជុំសំរបសំរួលការអនុវត្តន៍វិធីសាស្ត្រឆ្លើយតបរួមគ្នា
# ក្នុងខេត្តសៀមរាប និង ខេត្តព្រៃវែង

**១. កាលបរិច្ឆេទ:** ថ្ងៃទី ១៦- ១៧ ខែ សីហា ឆ្នាំ ២០១០

**២. ទីកន្លែង:** បន្ទប់ប្រជុំនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍សើស្បែក និងកាមរោគ

**៣. ឧបត្ថម្ភដោយ:** មូលនិធិ **GFATMR4P$_2$** នៃក្រសួងសុខាភិបាល

## ៤. គោលបំណង:

–ផ្តល់ចំណេះដឹងបន្ថែមដល់អ្នកសំរបសំរួលការអនុវត្តន៏វិធីសាស្ត្រឆ្លើយតបរួមនៅថ្នាក់ស្រុក ប្រតិបតិបត្តិអំពីការដឹកនាំល្អ និងតាមដានរាល់សមាសភាគទាំងអស់របស់យុទ្ធឆ្លើយតបរួមគ្នា។

– ធ្វើអោយប្រសើរឡើងនូវវគ្គបណ្តុះបណ្តាលដោយរំលឹករាល់សមាសភាគក្នុងការប្រតិបត្តិវិធី សាស្ត្រ ឆ្លើយតបរួមគ្នា។

-បង្កើតឡើងនូវដំណើរការប្រព្រឹត្តទៅនៃដំណើរ ផែនការ និង សំភារៈបរិក្ខារថ្នាក់ជាតិក្នុងការ អនុវត្តន៏វិធីសាស្ត្រឆ្លើយតបរួមគ្នា។

## ៥. សមាសភាពចូលរួម:

ក/ អ្នកសំរបសំរួល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគរួមមាន:

- វេជ្ជ. លឹម យី — អនុប្រធានមជ្ឈមណ្ឌលជាតិ
- វេជ្ជ. សេង សុភាព — អនុប្រធានមជ្ឈមណ្ឌលជាតិ
- វេជ្ជ. សរិត សុវណ្ណរិទ្ធ — ប្រធានផ្នែកថែទាំជំងឺអេដស៍
- វេជ្ជ. ង៉ូវ បូរ៉ា — មន្ត្រីផ្នែកថែទាំជំងឺអេដស៍
- វេជ្ជ. ទូច សារុន — មន្ត្រីផ្នែកថែទាំជំងឺអេដស៍
- វេជ្ជ. ស៊ុយ ដូនីន — មន្ត្រីផ្នែកថែទាំជំងឺអេដស៍

ខ/ វាគ្មិនមកពី NCHADS & NMCH ចំនួន ៤ នាក់

- លោកស្រី ទួន សុវណ្ណា — NMCHC
- លោកស្រី ហង្ស វណ្ណារី — NMCHC

- លោក ទី ស៊ីណារ៉ូ LMU
- លោក ស៊ុន សុខ លេង DMU

គ/ សិក្ខាកាមចូលរួមមាន :

១. ខេត្តសៀមរាប: ចំនួន ៥ នាក់ មកពីស្រុកប្រតិបត្តិសៀមរាប

២. ខេត្តព្រៃវែង: ចំនួន ២០ នាក់ក្នុងនោះមានស្រុកប្រតិបត្តិស្វាយអន្ទរ ៥ នាក់ ស្រុកប្រតិបត្តិ កំចាយមារ ៥ នាក់ និងស្រុកប្រតិបត្តិពារាំង ៥ នាក់។

៣. អង្គការដៃគូ : ៣នាក់ ក្នុងនោះមាន តំណាងអង្គការ Caritas ប្រចាំស្រុកប្រតិបត្តិសៀមរាប CLA ប្រតិបត្តិការ ក្នុងខេត្តព្រៃវែង ។

សិក្ខាកាមថ្នាក់ខេត្ត: ៥នាក់ក្នុងនោះមានប្រធានកម្មវិធីអេដស៍ខេត្ត១នាក់ អ្នកសំរបសំរួល CoC ១នាក់ TB ១នាក់ MCH ១ នាក់និងអ្នកគ្រប់គ្រងទិន្នន័យ ១នាក់ ។

សិក្ខាកាមថ្នាក់ស្រុកប្រតិបត្តិនិមួយៗ : ៥ នាក់ក្នុងនោះមានប្រធានស្រុកប្រតិបត្តិ១នាក់ អ្នកសំរបសំរួលការអនុវត្តន៏វិធីសាស្រ្តឆ្លើយតបរួមគ្នា ១នាក់ TB ១នាក់ MCH១ នាក់ និងអ្នកគ្រប់គ្រង ទិន្នន័យ ១នាក់ ។

## ៦- សកម្មភាពៈ

## ថ្ងៃទី ១

ពិធីបើកកិច្ចប្រជុំដោយវេជ្ជ. មាន ឈីវុន ប្រធាន NCHADS

បន្ទាប់ពីបញ្ចប់ពិធីបើកកិច្ចប្រជុំមកយើងបានពិភាក្សាលើការស្វែងយល់ពីដំណាក់កាលជាបន្ត បន្ទាប់នៃការព្យាបាលថែទាំក្នុងការអនុវត្តន៏វិធីសាស្រ្តឆ្លើយតបរួមគ្នាដោយចែកសិក្ខាកាមជាក្រុមតូច ដោយធ្វើការពិភាក្សាក្រុមតូច រយៈ ពេល ១ម៉ោង ដោយចែកសិក្ខាកាមជា ៥ក្រុម ពិភក្សាចំរុះគ្នាដោយក្រុម នីមួយៗមានសមាជិកចំនួន ៦នាក់អោយពិ ភាក្សាលើ ប្រធានបទ:

១. សេវាពិនិត្យផ្ទៃពោះមុនពេលសំរាលក្នុងការចូលរួមអនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នា

២. សេវាធ្វើតេស្តឈាមរកមេរោគអេដស៏ក្នុងការចូលរួមអនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នា

៣. សេវាសំរាលកូនក្នុងការចូលរួមអនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នា

៤. ការថែទាំ និងការធ្វើតេស្តឈាមស្ទួតរបស់ទារកដែលកើតពីម្តាយផ្ទុកមេរោគអេដស៏ក្នុងការចូលរួមអនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នា ។

៥. ក្រុមថែទាំតាមផ្ទះ ក្នុងការចូលរួមអនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នាបន្ទាប់មកទៀតយើងអោយ :

- សមាជិកក្រុមធ្វើកាងាររួមគ្នា រៀបចំការបង្ហាញ ទាក់ទងនឹងប្រធានបទ រៀបរាប់ពីការព្យាបាល ថែទាំ ក្នុងបរិបទនៃវិធីសាស្រ្តឆ្លើយតបរួមគ្នាទាំង ៥ ខាងលើ។
- ការបង្ហាញរបស់ក្រុមតូចៗ ។

បន្ទាប់មកទៀតយើងអោយធ្វើការពិភាក្សាក្រុមធំដែលមានរយៈពេល ១ម៉ោងដោយអោយ :

- ក្រុមតូចៗនីមួយៗបង្ហាញនូវលទ្ធផលនៃការពិភាក្សារបស់ខ្លួនដល់ក្រុមធំ

- ក្រោយពេលចប់ការបង្ហាញនីមួយៗ បើកឱកាសអោយមានសំនួរការបំភ្លឺ និងការផ្តល់អនុសាសន៍ពី ក្រុមធំ និងមានការសំរបសំរួលពីអ្នកសំរបសំរួលពីបុគ្គលិក NCHADS & MCH ។

បន្ទាប់មកទៀតយើងពិភាក្សាលើសេណារីយ៉ូដែលក្នុងផ្នែកនេះនឹងផ្តល់ឱកាសដល់អ្នកសំរបសំរួលវិធីសាស្ត្រឆ្លើយតបរួមគ្នាសិក្សាពីករណីសិក្សាមួយចំនួនដើម្បីបញ្ជាក់និង បន្ថែមនូវការថែទាំ/ព្យាបាល ដែលមាននៅក្នុងតំណាក់កាលបន្តបន្ទាប់របស់ PMTCT ក្នុងបរិបទនៃវិធីសាស្ត្រឆ្លើយតបរួមគ្នា។ ដោយធ្វើការពិភាក្សាក្រុមធំរយៈពេល១ម៉ោង :

- សេណារីយ៉ោផ្សេងៗចំនួន១៥ ទាក់ទងនឹងការថែទាំ/ព្យាបាលដែលមានក្នុងតំណាក់កាលបន្តបន្ទាប់នៃ PMTCT ក្នុង វិធីសាស្ត្រឆ្លើយតបរួមគ្នា នឹងត្រូវសរសេរលើកាត ហើយដាក់ចូលក្នុងប្រអប់ហើយ :

- អ្នកសំរបសំរួលសិក្ខាសាលានឹងពន្យល់អំពីសកម្មភាពដែលត្រូវធ្វើដល់ក្រុមធំ ។អ្នកសំរបសំរួល នឹង ហៅសិក្ខាកាមមកខាងមុខក្រុមធំ ។ សិក្ខាកាមត្រូវចាប់យកកាតម្នាក់១សន្លឹកៗរួចឆ្លើយនឹងសំនួរដែលសរសេរក្នុងកាត។

- ក្រោយពេលចំឡើយនីមួយៗអ្នកសំរបសំរួលបើកឱកាសអោយក្រុមធំបញ្ចេញយោបល់ដោយមានការលើកទឹកចិត្តអោយមានយោបល់បំភ្លឺ និងកែតំរូវ ។

-កំណត់សំគាល់សំរាប់អ្នកសំរបសំរួល :សាកល្បងអោយសកម្មភាពទាំងអស់ផ្សារភ្ជាប់គ្នានិងមានការ ចូលរួមយ៉ាងសកម្ម។

## បញ្ជីតាមដាន

រៀបចំក្នុងគោលបំណងតាមដាន ច្បាស់លាស់អំពីវឌ្ឍនភាពរបស់អ្នកជំងឺតាមរយៈ PMTCT និងអាច ប្រមូលផ្តុំទិន្នន័យសំរាប់រាយការណ៍ ។ បញ្ជីតាមដានអ្នកជំងឺក្នុងវិធីសាស្ត្រឆ្លើយតបរួមគ្នាបង្កើត ឡើងសំរាប់សេវារណប។

**<u>ការបង្ហាញរបស់អ្នកសំរបសំរួល</u>( ១០នាទី)**

- អ្នកសំរបសំរួបសំរួលបង្ហាញ បកស្រាយពីសុច្ឆនាករតាមកូឡោនីមួយរបស់បញ្ជីតាមដាន ។
- អ្នកសំរបសំរបសំរួលត្រូវឆ្លៀតឱកាសនេះដើម្បីសង្កត់ធ្ងន់លើភាពម្ចាស់ការ (Ownership) លើ បញ្ជីតាមដាន និងរួមដៃគ្នាបន្តធ្វើបច្ចុប្បន្នលើបញ្ជីតាមដាន។

**<u>ការពិភាក្សាក្រុមតូច</u>( ១៥នាទី) :**

- ចែកសិក្ខាកាមជាក្រុមតូច ដោយក្រុមនីមួយៗមានសមាជិកចំនួន ៣នាក់ ។
- អ្នកសំរបសំរួលចែកទំរង់របាយការណ៍ដែលមានទិន្នន័យគ្រប់គ្រាន់ស្រាប់ដល់ក្រុមពិភាក្សានី មួយៗ ។ ទំរង់ របាយការដែលជាឧទាហរណ៍ នេះ មានកំហុសជាច្រើនដែលត្រូវកែសំរួល។
- សិក្ខាកាមធ្វើការជាក្រុមពិនិត្យរកកំហុសក្នុងទំរង់របាយការណ៍ ។

**<u>ការពិភាក្សាក្រុមធំ</u>( ១៥នាទី) :**

- អ្នកសំរបសំរួលដឹកនាំការពិភាក្សាលើឧទាហរណ៍ដែលបង្ហាញលើអេក្រង់ពីកំហុសដែលបានរក ឃើញក្នុងទំរង់របាយការណ៍ ។ការងារនេះសំដៅទៅរកការបញ្ជាក់ពិកំហុស និង ពីមូលហេតុនាំ អោយមានកំហុសនិងពីវិធីកែកំហុសក្នុងទំរង់របាយការណ៍ ។
- អ្នកសំរបសំរួលដើរតួនាទីជាបុគ្គលិកមណ្ឌលសុខភាពជាបុគ្គលិកក្រុមថែទាំតាមផ្ទះក្នុងការកែកំហុសដែលបានរកឃើញដោយក្រុមពិភាក្សា ។
- អ្នកសំរបសំរួលគួរអញ្ជើញតំណាងក្រុមផ្សេងៗ ដោយលើកទឹកចិត្តអោយសហការណ៍ពិភាក្សា លើលទ្ធផលដែលរកឃើញខាងលើ ។

**<u>ការបង្ហាញរបស់អ្នកសំរបសំរួល</u>(១០នាទី)**

- អ្នកសំរបសំរួលបានបង្ហាញពី Cohort tree ៗនេះបង្ហាញនូវចង្កោមសេវាំដែលផ្តល់ដោយវិធី សាស្ត្រឆ្លើយតបរួមគ្នា។ ការរៀបចំបង្កើត Tree reports នេះជាការទទួលខុសត្រូវរបស់មន្ត្រីផ្នែក ទិន្នន័យដែលត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ត្រីមាស ។Tree reports នេះនឹងត្រូវបង្ហាញនៅក្នុងកិច្ចប្រជុំ របស់ក្រុមការងារវិធីសាស្ត្រឆ្លើយតបរួមគ្នា ។
- អ្នកសំរបសំរួលនឹងតំរូវអោយសិក្ខាកាមម្នាក់ៗបំពេញ tree reports ដោយប្រើទិន្នន័យក្នុងបញ្ជីតាមដានដែលបានកែសំរួលរួចហើយ ។

**<u>ការងារសំរាប់សិក្ខាកាមម្នាក់ៗ</u> (២០នាទី)**

- សិក្ខាកាមត្រូវបង្កើត Tree reports ដោយប្រើប្រាស់ទិន្នន័យដែលបានកែតំរូវរួចក្នុងទំរង់របាយការណ៍ ។
- លើកទឹកចិត្តសិក្ខាកាមអោយធ្វើការជាមួយគ្នាក្នុងករណីយល់ពុំច្បាស់ ។អ្នកសំរបសំរួលគួរសង្កេតពិនិត្យលើការងារ និង បំភ្លឺនូវរាល់សំនួរ ។

**<u>ការពិភាក្សាក្រុមធំ</u>(២០នាទី):**

- បញ្ចាំង Tree reports ដែលពុំមានទិន្នន័យនៅលើអេក្រង់ អ្នកសំរបសំរួលលើកទឹកចិត្តសិក្ខាកាមអោយ ធ្វើការបំពេញ Tree reports ជាមួយគ្នា ។
- អ្នកសំរបសំរួលគួរអញ្ជើញតំណាងក្រុមផ្សេងៗ ដោយលើកទឹកចិត្តអោយសហការណ៍ពិភាក្សាលើលទ្ធផលដែលរកឃើញខាងលើ ។
- អ្នកសំរបសំរួលគួរឆ្លៀតឱកាសនេះដើម្បីពង្រឹងតំណាក់កាលបន្តបន្ទាប់នៃការថែទាំ និងព្យាបាល ក្នុងវិធីសាស្ត្រឆ្លើយតបរួមគ្នា ឆ្លើយបំភ្លឺនូវរាល់សំនួរ ឬកង្វល់ដែលបង្ហាញដោយក្រុមធំ ។

# ថ្ងៃទី២

**ការបង្ហាញរបស់ផ្នែកសំភារៈ បរិក្ខា** (រយៈពេល១០នាទី)

- ការបង្ហាញដោយ PowerPoint អ្នកសំរបសំរួលផ្នែកសំភារៈ បរិក្ខា របស់ NCHADS នឹង បង្ហាញនូវលំហូបែបបទនៃសំណើសុំសំភារៈបរិក្ខារៀងរាល់ត្រីមាស និងពន្យល់បង្ហាញតាមលំ ដាប់លំដោយនៃសំណើរនោះ ។
- អ្នកសំរបសំរួលផ្នែកសំភារៈ បរិក្ខា របស់ NCHADS នឹងប្រើប្រាស់ឱកាសនេះដើម្បីបញ្ជាក់ អោយច្បាស់នូវរាល់សំណួរ ឬកង្វល់ដែលបង្ហាញដោយក្រុមធំដែល ទាក់ទងនឹងសំភារៈបរិក្ខា ។

**ពិភាក្សាក្រុមតូច** (រយៈពេល២០នាទី)

- ក្រុមធំត្រូវបំបែកទៅជាក្រុមតូចតាមខេត្តនីមួយៗ
- ស្រុកប្រតិបត្តិនិមួយៗនឹងពិភាក្សាអំពីសំភារៈបរិក្ខាសំរាប់ការអនុវត្តន៏វិធីសាស្រ្តឆ្លើយតបរួមគ្នាក្នុងខេត្តផ្ទាល់ខ្លួន ។
- អ្នសំរបសំរួលសាកសួរក្រុមពិភាក្សានីមួយៈតាមសំនួរដូចខាងក្រោម :
  - -តើអ្វីជាបញ្ហាទាក់ទងនឹងការផ្តល់សំភារៈបរិក្ខាសំរាប់អនុវត្តវិធីសាស្រ្តឆ្លើយតបរួមគ្នា ក្នុងខេត្តរបស់អ្នក?
  - -តើអ្វីជាដំណោះស្រាយសំរាប់បញ្ហាខាងលើនេះ?
- ខេត្តនិមួយៗត្រូវកំណត់ពីមធ្យោបាយដ៏ប្រសើរជាមួយនិងសិក្ខាកាមក្នុងខេត្តដើម្បីធ្វើការបែងចែកសំភារៈបរិក្ខាពីស្រុកប្រតិបត្តិទៅមណ្ឌលសុខភាពអោយបានរលូន ។
- អ្នកសំរបសំរួលផ្នែកសំភារៈបរិក្ខារបស់ NCHADS ត្រូវចូលតាមក្រុមពិភាក្សានីមួយៗដើម្បីស្តាប់ការជជែកផ្តល់ការណែនាំ និងឆ្លើយសំនួរ ។

**ពិភាក្សាក្រុមធំ** (រយៈពេល២០នាទី)

- សិក្ខាកាមត្រឡប់មកចូលរួមជាមួយក្រុមធំវិញ អ្នកសំរបសំរួលផ្នែកសំភារៈបរិក្ខារបស់ NCHADS ត្រូវដឹកនាំការពិភាក្សាលើលទ្ធផលពិភាក្សរបស់ក្រុមតូច ។
- ដោយប្រើ ការបញ្ចាំងលើ Screen អ្នកសំរបសំរួលផ្នែកសំភារៈ បរិក្ខា របស់ NCHADS ត្រូវកត់ត្រាគំនិតទាំងអស់សំរាប់បង្ហាញ ដល់ក្រុមធំ ។
- បន្ទាប់មកទៀតអ្នកសំរបសំរួលផ្នែកសំភារៈបរិក្ខារបស់ NCHADS នឹងបង្ហាញពីការសង្កត និងអនុសាសន៍ដែលគាត់រកឃើញក្នុងពេលពិភាក្សាតាមក្រុមតូច ។

## កិច្ចប្រជុំសំរបសំរួលប្រចាំត្រីមាស

**<u>អ្នកសំរបសំរួលបង្ហាញអំពីរបៀបរៀបចំកិច្ចប្រជុំសំរបសំរួល</u>** (រយៈពេល៣០នាទី)

- ការបង្ហាញដោយ Power point ។
- ការបង្ហាញនេះត្រូវធ្វើឡើងដោយមានការចូលរួមពីសិក្ខាកាម ។
- អ្នកសំរបសំរួលត្រូវធ្វើយ៉ាងណាអោយសិក្ខាកាមចូលរួម សួរសំនួរដើម្បីបំផុសគំនិត ។ ជាឧទាហរណ៍ ទិនន័្នយដែលត្រូវផ្តល់ត្រឡប់ទៅវិញក៏ត្រូវបង្ហាញក្នុងកិច្ចប្រជុំនេះដែរ ។

**<u>អ្នកសំរបសំរួលបង្ហាញចំពោះក្រុមធំ-របាយការណ៍ត្រីមាស</u>** (រយៈពេល៥នាទី)

- រៀបរាប់អោយបានល្អិតល្អន់នូវសុចនាករ(Indicator) និមួយៗដែលត្រូវពន្យល់លំអិតក្នុង វគ្គសិក្សាដែល សិក្ខាកាមនិមួយៗនឹង ទទួលបាននៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាលនេះ ។
- អ្នកសំរបសំរួលនឹងបង្ហាញនូវរបាយការណ៍រាល់ខែ និងរាល់ត្រីមាស ដែលបង្ហាញជាសង្ខេប ដោយ Power point

## ការចុះអភិបាល

**<u>ពិភាក្សាក្រុមតូច</u>** (រយៈពេល៣០នាទី)

- បំបែកក្រុមធំជាក្រុមតូចចំនួន៥ក្រុម ដែលក្នុង១ក្រុមៗមានសមាជិកចំនួន៥នាក់
- សួរក្រុមនិមួយៗដើម្បីបង្កើតនូវប័ណ្ណចុះពិនិត្យ(Checklist)ពន្យល់ថានេះជាតារាងបញ្ជីមួយដែលចាំបាច់ត្រូវត្រួតពិនិត្យនៅពេលចុះអភិបាលពីស្រុកប្រតិបត្តិទៅមណ្ឌលសុខភាព ។
- សួរក្រុមនិមួយៗអោយមានយោបល់ពីតារាងបញ្ជីនោះហើយអ្នកណាខ្លះដែលត្រូវចូលរួមក្នុងការចុះអភិបាលពីស្រុកប្រតិបត្តិទៅមណ្ឌលសុខភាព ។
- សួរក្រុមនិមួយៗដោយបំផុសគំនិតដល់សិក្ខាកាម រកវិធីយ៉ាងណាត្រូវផ្តល់ពត៌មានត្រឡប់ទៅ មណ្ឌលសុខភាពវិញបន្ទាប់ពីបានបញ្ចប់ការចុះអភិបាល ។
- ត្រូវមានលេខាកត់ត្រាតាមក្រុមនិមួយៗ ដើម្បីបានជាគំនិតរបស់ក្រុម ។

**<u>ពិភាក្សាក្រុមធំ</u>** (រយៈពេល២៥នាទី)

- សិក្ខាកាមទាំងអស់នឹងត្រូវវិលចូលទៅក្នុងក្រុមធំវិញនិងអ្នកសំរបសំរួលនឹងដឹកនាំការពិភាក្សានូវគំនិតរបស់ក្រុមនិមួយៗដែលបានបញ្ចេញ ។

- តាមរយៈការបញ្ចាំងបង្ហាញ អ្នកសំរបសំរួលនឹងបង្កើតបាននូវតារាងចុះត្រួតពិនិត្យមួយដោយ ធ្វើការចងក្រង នូវគំនិតតាម ក្រុមនិមួយៗដើម្បីធ្វើការបង្ហាញ។អ្នកសំរបសំរួល ក៏ធ្វើដូចគ្នានេះ ដែរនូវគំនិតនូវការផ្តល់ពត៌មានត្រឡប់ទៅមណ្ឌលសុខភាពនៅពេលចុះអភិបាល ។
- អ្នកសំរបសំរួលត្រូវប្រាប់ទៅតំណាងក្រុមនិមួយៗ អោយលើកទឹកចិត្តក្នុងកិច្ចសហការណ៏ និង ចូលរួមក្នុងសកម្មភាព។

__ការបង្ហាញក្រុមធំ-ការចុះបញ្ជី__ (រយៈពេល៥នាទី)

- ដោយការបង្ហាញដោយ PowerPoint អ្នកសំរបសំរួលបង្ហាញដោយសង្ខេបនូវរាល់រូបភាពសៀវភៅចុះបញ្ជីក្នុងការអនុវត្តន៏នូវវិធីសាស្ត្រឆ្លើយតបរួមគ្នា។
- អ្នកសំរបសំរួល នឹងប្រើប្រាស់ឳកាសនេះដើម្បីបញ្ជាក់អោយច្បាស់រាល់ សំណួរឬកង្វល់ផ្សេងៗ ដែលបង្ហាញដោយក្រុមធំ ដែល ទាក់ ទងនឹងសៀវភៅចុះបញ្ជី។

## អង្គការដៃគូ និងអ្នកសំរបសំរួលក្រុមថែទាំតាមផ្ទះ

__ការបង្ហាញរបស់ស្រុកប្រតិបត្តិ__ (រយៈពេល១៥នាទី)

- ជ្រើសរើសស្រុកប្រតិបត្តិ ឬខេត្តណាមួយដើម្បីបង្ហាញពីបទពិសោធន៏របស់ពួកគេ ក្នុងការសំរបសំរួលរវាង ក្រុមថែទាំតាមផ្ទះ និងអង្គការដៃគូ នៅក្នុងវិធីសាស្ត្រឆ្លើយតបរួមគ្នា ។ ការបង្ហាញ នេះមានរយះពេល ១០នាទី។
- ស្រុកប្រតិបត្តិដែលជាគំរូនឹងបង្ហាញនូវចំណុចលំបាកសំខាន់ៗនិងជោគជ័យរបស់គាត់ក្នុងការសំរបសំរួលជាមួយក្រុមថែទាំតាមផ្ទះ និងអង្គការដៃគូ។
- នៅចុងបញ្ចប់នៃការបង្ហាញរយៈពេលខ្លីនេះអ្នកសំរបសំរួលនឹងបើកអោយមានកិច្ចពិភាក្សាដើម្បីផ្តល់អនុសាសន៏សួរសំនួរ ឆ្លើយពន្យល់ និងបញ្ជាក់ អោយបានច្បាស់។

__ធ្វើការជាក្រុមតូច__ (រយៈពេល៣០នាទី)

- បំបែកក្រុមធំ ទៅជាក្រុមតូចតាម ខេត្ត ឬ ស្រុកប្រតិបត្តិនិមួយៗរបស់សិក្ខាកាម ។
- រាល់ស្រុកប្រតិបត្តិនិមួយៗនឹងត្រូវពិភាក្សាពីការសំរបសំរួលរវាងក្រុមថែទាំតាមផ្ទះ និងអង្គការ ដៃគូនៅក្នុងស្រុកប្រតិបត្តិផ្ទាល់របស់គាត់។
- អ្នកសំរបសំរួលនឹងសួរទៅក្រុមពិភាក្សានិមួយៗនូវសំនួរដូចខាងក្រោមនេះ :
  - អង្គការណាដែលជាដៃគូរបស់អ្នក
  - តើអ្នកមានគិតពីការលំបាក ដែលនឹងអាចកើតមាននៅពេលអនុវត្តវិធីសាស្ត្រឆ្លើយតបរួមគ្នា?តើអង្គការជាដៃគូជួយរបៀបណាខ្លះលើការលំបាកទាំងនេះ?

- ជ្រើសរើសនូវគំនិតមួយ ដើម្បីអោយបានសំរេចជោគជ័យក្នុងការសំរបសំរួលជាមួយ អង្គការដៃគូរបស់អ្នក។

■ ក្រុមនិមួយៗត្រូវកត់ត្រានូវចំលើយរបស់គាត់។

**ពិភាក្សាក្រុមធំ** (រយៈពេល១៥នាទី)

■ សិក្ខាកាមទាំងអស់នឹងវិលចូលទៅក្រុមធំវិញ ហើយអ្នកសំរបសំរួលនឹងដឹកនាំការពិភាក្សានូវ គំនិតរបស់ក្រុមនិមួយៗ ដែលបានគិតឃើញ និងលើកឡើង។

■ ដោយប្រើប្រាស់ projected screen អ្នកសំរបសំរួលនឹងសួរនូវសំនួរដូចខាងក្រោមទៅក្រុមធំ :

- តើអ្នកគិតថានឹងមានការលំបាកអ្វីក្នុងការអនុវត្តិវិធីសាស្ត្រឆ្លើយតបរួមគ្នា ? តើអង្គការ ជាដៃគូរជួយរបៀបណាខ្លះ លើការលំបាកទាំងនេះ ?

■ អ្នកសំរបសំរួលត្រូវកត់ត្រានូវចំឡើយរបស់ក្រុមនីមួយៗលើ Screen ដើម្បីបង្ហាញក្រុមធំ ។

■ អ្នកសំរបសំរួលបានប្រាប់ទៅតំណាងមកពីក្រុមនិមួយៗអោយមានចិត្តក្លាហានក្នុងការសហការណ៍ និងចូលរួមក្នុង សកម្មភាពការងារក្នុងស្រុកប្រតិបត្តិនិមួយៗ។

## ៧. ការសន្និដ្ឋាន

អង្គប្រជុំនេះបានបញ្ចប់នៅម៉ោង ១៧:០០ នាទីល្ងាចថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០ បន្ទាប់ពី បានធ្វើការណែនាំផ្តាំផ្ញើរដល់សិក្ខាកាមអោយអនុវតន៏ការងារដោយយកចិត្តទុកដាក់ខ្ពស់និងមានការសហការគ្នាអោយបានល្អ ក្រោមអធិបតីភាព ឯកឧត្តម វេជ្ជ. មាន ឈីវុន ប្រធានមជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

បានឃើញ និង ឯកភាព
ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធ
នឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

វេជ្ជ មាន_ឈីវុន

ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១០
អ្នកធ្វើរបាយការណ៍

វេជ្ជ. ង៉ូវ បូរ៉ា